សហការ

ទាំងអស់គ្នាដើម្បីភាពរីកចម្រើន!

# ២០២៤
# របាយការណ៍ប្រចាំឆ្នាំ

www.sahakamfi.com.kh Sahaka MFI Sahaka_MFI Sahaka_MFI Sahaka MFI

០២៣ ៩៦៧ ៧៧៩,០៦១ ៥០០ ៩៧៩,០៩៣ ៥០០ ៩៧៩ #៦CD, មហាវិថី សាធារណរដ្ឋ ប៉ូឡូញ (១៦៣), សង្កាត់វាលវង់ ខណ្ឌ ៧មករា, រាជធានីភ្នំពេញ

# មាតិកា

០១

សារពីប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ ០១

០២

## អំពី សហការ

អំពីយើងខ្ញុំ ០៣
ចក្ខុវិស័យ បេសកកម្ម គុណតម្លៃ ០៤
ផលិតផលរបស់យើង ០៥
សមត្ថិផលសំខាន់ៗ ០៦
រំលេចព័ត៌មានប្រតិបត្តិការសំខាន់ៗ ០៧
រំលេចព័ត៌មានហិរញ្ញវត្ថុសំខាន់ៗ ០៨
សក្ខីភាពពីអតិថិជន ០៩

០៣

## អភិបាលកិច្ចសាជីវកម្ម

សារពីអភិបាលសាជីវកម្ម ១១
ក្រុមប្រឹក្សាភិបាល ១២
កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ១៣
គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ១៤
គណៈកម្មាធិការនាយកប្រតិបត្តិ (EXCOM) ១៥
រចនាសម្ព័ន្ធគ្រប់គ្រង ១៦

០៤

## ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

ការគ្រប់គ្រងហានិភ័យ ១៧
ការប្រតិបត្តិទៅតាមបទប្បញ្ញត្តិ និងការរាយការណ៍របាយការណ៍ហិរញ្ញវត្ថុ ១៨

០៥

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ១៩



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

អាជ្ញាបណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
MICROFINANCE INSTITUTION LICENSE

លេខ : ម.ហ.៦៧
N° : M.F.67

ធនាគារជាតិ នៃ កម្ពុជា

អនុញ្ញាតឱ្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានទីស្នាក់ការកណ្ដាលតាំងនៅ ដីឡូត៍លេខ៦សេដេ ផ្លូវលេខ ១៦៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ស្ដីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិ សារាចរណែនាំ វិធាន ព្រមទាំងលក្ខខណ្ឌទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា។

THE NATIONAL BANK OF CAMBODIA

allows SAHAKA MICROFINANCE INSTITUTION PLC. to carry out operations as microfinance institution with head office at Slot N° 6CD, Street N° 163, Sangkat Veal Vong, Khan Prampir Meakkakra, Phnom Penh.

SAHAKA MICROFINANCE INSTITUTION PLC. shall abide by the Law on Banking and Financial Institutions and all regulations, circulars, rules, and conditions issued by the National Bank of Cambodia.

ថ្ងៃចន្ទ ៩កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣
Phnom Penh, 26 June 2023

ទេសាភិបាល
Governor

ជា_ចាន់តូ

- អាជ្ញាបណ្ណនេះ មានសុពលភាពរហូតដល់ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥
- អាជ្ញាបណ្ណនេះ ត្រូវព្យួរបង្ហាញសាធារណជនគ្រប់ពេលវេលា

- This license is valid until 08 April 2025.
- This license shall be displayed to the public at all times.



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

លេខ(No) MOC-76385478 ពណ.ចបព

វិញ្ញាបនបត្រ
បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
CERTIFICATE OF INCORPORATION

| | | |
|---|---|---|
| នាមករណ៍ | : | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភិអិលស៊ី |
| NAME | : | SAHAKA MICROFINANCE INSTITUTION PLC. |
| ចុះបញ្ជីក្រោមលេខ | : | 00005854 |
| REGISTRATION NUMBER | : | 00005854 |
| អត្តលេខចុះបញ្ជីចាស់ | : | Co. 4361E/2015 |
| OLD REGISTRATION NUMBER | : | Co. 4361E/2015 |
| កាលបរិច្ឆេទចុះក្នុងបញ្ជីពាណិជ្ជកម្ម | : | 08 ធ្នូ 2015 |
| INCORPORATION DATE | : | 08 December 2015 |
| ត្រូវបានទទួលស្គាល់ថាជា: | : | ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត |
| IS INCORPORATED AS: | : | Public Limited Company |

ភ្នំពេញ, 08 ធ្នូ 2015
PHNOM PENH, 08 DECEMBER 2015
ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
F. MINISTER OF COMMERCE
អគ្គនាយក
Director General
ហូ_ស៊ីវយ៉ុង
HO SIVYONG

ស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE AND PENAL CODE OF THE KINGDOM OF CAMBODIA



ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
លេខ/N°PTM25012048876 អពដ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០២៥
អ្នកជាប់ពន្ធមធ្យម

ឈ្មោះសហគ្រាស៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី
លេខអត្តសញ្ញាណកម្មសារពើពន្ធ៖ K004-901504719
ចុះបញ្ជីនៅ៖ អគ្គនាយកដ្ឋានពន្ធដារ ស្ថិតនៅក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខណ្ឌ៧មករា
ទម្រង់សហគ្រាស៖ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
សកម្មភាពអាជីវកម្មបន្ទាប់បន្សំ៖ អចលនទ្រព្យ (ទិញ លក់ និងជួល)
អាសយដ្ឋានសហគ្រាស៖ #ដីឡូត៍លេខ ៦CD ផ្លូវ១៦៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ឈ្មោះម្ចាស់សហគ្រាស៖ បុល វ៉ាន់នៀត សញ្ជាតិ៖ ខ្មែរ

PATENT TAX 2025
Medium Taxpayer

Company's name : SAHAKA MICROFINANCE INSTITUTION PLC.
Tax Identification Number (TIN) : K004-901504719
Registered at : General Department of Taxation Under : 7 Makara Tax Branch
Additional business activity(ies) : Real estate (buying, selling and renting)
Forms of business : Public limited company
Owner's name : BOL VANNEAT Nationality: Cambodian

ទឹកប្រាក់ពន្ធប៉ាតង់ ២០២៥
១,២០០,០០០ រៀល
លេខ SN: 010664078

អគ្គនាយកដ្ឋានពន្ធដារ
General Department of Taxation
បោះពុម្ពនៅ / Printed at
ធនាគារ អេស៊ីលីដា
ACLEDA Bank

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥
Phnom Penh,20 January 2025

បញ្ជាក់ ៖ ប័ណ្ណប៉ាតង់នេះត្រូវដាក់តាំង ឬព្យួរ នៅទីកន្លែងប្រកបអាជីវកម្ម។
Note : This patent tax must be hanged or displayed at the company's office.

# ១

# សារពីប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ



**លោក បុល វ៉ាន់នៀត**

**ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ**

# សារពីប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ

## *ជូនចំពោះម្ចាស់ភាគហ៊ុន អ្នកវិនិយោគ និងអតិថិជនជាទីគោរព!*

**“ ក្នុងនាមតំណាងគណៈក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ខ្ញុំបាទមានកិត្តិយស និងរាយការណ៍អំពីសមិទ្ធផលសំខាន់ៗរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ដែលសម្រេចបាន ក្នុងឆ្នាំ២០២៤។ ”**

ក្នុងខណៈដែលយើងបង្ហាញរបាយការណ៍ប្រចាំឆ្នាំ ២០២៤ នេះ យើងបានឆ្លុះបង្ហាញថានេះជាឆ្នាំ ដែលស្ថិតក្នុងដំណើរការ ការសម្របតាម និងជាឆ្នាំដែលស្ថិតក្នុងបំណងនៃការរីកចម្រើនរបស់យើង។ បើទោះបីជាមានបញ្ហាប្រឈម វាក៏ជាឱកាស ដែលយើងអាចបន្តអនុវត្តបេសកកម្មក្នុងការលើកស្ទួយដល់ជីវភាពបុគ្គលកសាងសហគមន៍ និងរួមចំណែកយ៉ាងមានន័យដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា។

### ចក្ខុវិស័យយុទ្ធសាស្ត្រ៖ ការលើកកម្ពស់អនាគត

ចំណុចស្នូលនៃយុទ្ធសាស្ត្ររបស់យើងគឺចក្ខុវិស័យ រយៈពេលវែង៖ ដើម្បីក្លាយជាដៃគូហិរញ្ញវត្ថុ ដែលអតិថិជនទុកចិត្ត ដែលអាចជួយជម្រុញការរីកចម្រើនសេដ្ឋកិច្ច និងកសាងនិរន្តរភាពនៃជីវភាពរស់នៅ របស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់។ ក្នុងឆ្នាំ ២០២៤ យើងបានដើរដល់កម្រិតជាក់លាក់ក្នុងទិសដៅនេះ ដោយបានពង្រីកតំបន់ប្រតិបត្តិការ បង្កើនសមត្ថភាពប្រតិបត្តិ និងបង្កើនគុណភាពសេវាកម្ម ឱ្យឆ្លើយតបជាពិសេសចំពោះអតិថិជននៅទីជនបទ និងតំបន់ដែលមិនមានសេវាហិរញ្ញវត្ថុគ្របដណ្ដប់ ។

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៤

យើងមានសេចក្ដីរីករាយក្នុងការបង្ហាញនូវសមិទ្ធផលនិងការអភិវឌ្ឍយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

• **អតិថិជន និងផលបត្រឥណទាន៖** ក្រោមការគ្រប់គ្រងហានិភ័យយ៉ាងសមស្រប យើងបានរក្សាកម្រិតស្ថេរភាព ព្រមទាំងបង្កើន គុណភាពនៃផលបត្រឥណទាន។ ដូចគ្នានេះដែរ យើងបានពង្រឹកមូលដ្ឋានប្រតិបត្តិការ ដោយសម្រេចនិងទទួលបានការពេញចិត្តខ្ពស់ពី អតិថិជន។

• **ការកសាងសមត្ថភាព៖** យើងបន្តវិនិយោគលើការអភិវឌ្ឍសមត្ថភាព ដោយផ្តល់ការបណ្តុះបណ្តាលនៅគ្រប់សាខា។ ការខិតខំទាំងនេះ ធ្វើឱ្យបុគ្គលិករបស់យើងមានសមត្ថភាពក្នុងការផ្តល់ សេវាហិរញ្ញវត្ថុ ប្រដោយមានវិជ្ជាជីវៈសេចក្ដីថ្លៃថ្នូរ និងការយល់ដឹង។

• **ការកែសម្រួលយុទ្ធសាស្ត្រ៖** ឆ្នាំ២០២៤គឺជាចំណុចផ្លាស់ប្តូរសំខាន់សម្រាប់សហការ ដោយយើងបានអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងយ៉ាងសំខាន់ដើម្បីវាយតម្លៃទិសដៅរយៈពេលវែង។ ជាលទ្ធផលយើងបានធ្វើបច្ចុប្បន្នភាពលើចក្ខុវិស័យបេសកកម្ម និងគុណតម្លៃស្នូលរបស់យើង ដើម្បីឆ្លុះបញ្ចាំងពីគោលដៅ និងការតាំងចិត្តដើម្បីនិរន្តរភាព និងការរីកចម្រើនសម្រាប់សហគមន៍ដែលយើងបម្រើ ។

## ការត្រួសត្រាយតាមរយៈលក្ខខ័ណ្ឌសេដ្ឋកិច្ច

សេដ្ឋកិច្ចនៃប្រទេសកម្ពុជា បានបង្ហាញនូវសភាពស្តារឡើងវិញយ៉ាងស្ថិតស្ថេរនៅក្នុងឆ្នាំ ២០២៤ បន្ទាប់ពីការប្រឈមក្នុងតំបន់ ក្នុងរយៈពេលកន្លងមក។ ខណៈដែលវិស័យទេសចរណ៍និងឧស្សាហកម្មបានចាប់ផ្តើមសកម្មភាពឡើងវិញ សហគមន៍ជនបទនៅតែប្រឈមនឹងហានិភ័យពីអាកាសធាតុ និងការប្រែប្រួលតម្លៃនៅលើទីផ្សារពិភពលោក។

ក្នុងបរិបទនេះ តួនាទីរបស់យើងក្នុងនាមជាគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ មានសារៈសំខាន់ជាងពេលណាទាំងអស់។ តាមរយៈការផ្តល់លទ្ធិភាព ទទួលបាននូវហិរញ្ញវត្ថុ កាលើកកម្ពស់តរិយបថហិរញ្ញវត្ថុ ប្រកបដោយការទទួលខុសត្រូវ និងការគាំទ្រសហគ្រាសខ្នាតតូច យើងបានរួមចំណែក ក្នុងការធានាស្ថិរភាពហិរញ្ញវត្ថុ និងលើកកម្ពស់ការកៀរគរសេដ្ឋកិច្ចសម្រាប់ប្រជាពលរដ្ឋជាងពាន់គ្រួសារ។

## តួនាទី និងការទទួលខុសត្រូវរបស់យើង

យើងមិនមែនគ្រាន់តែជាអ្នកផ្តល់សេវាហិរញ្ញវត្ថុប៉ុណ្ណោះទេ តែយើងជាចលករជម្រុញឲ្យមានបម្រែបម្រួល។ វិធីសាស្ត្ររបស់យើងផ្អែកលើការផ្តល់ឥណទានប្រកបដោយទំនួលខុសត្រូវ ការពារអតិថិជន និងដៃគូរយៈពេលវែង ជាមួយសហគមន៍ ដែលយើងធ្វើការជាមួយ។ យើងធ្វើការយ៉ាងជិតស្និទ្ធ ជាមួយធនាគារជាតិនៃកម្ពុជា និងគោរពតាមបច្ចេកទេស នៃបទបញ្ញា ដើម្បីធានាតម្លាភាពនៃហិរញ្ញវត្ថុ ភាពទទួលខុសត្រូវខ្ពស់ និងក្រមសីលធម៌វិជ្ជាជីវៈ។

## ការប្តេជ្ញាចំពោះការរួមបញ្ចូលផ្នែកហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ការប្តេជ្ញាចិត្តដ៏រឹងមាំរបស់យើងចំពោះការរួមបញ្ចូលផ្នែកហិរញ្ញវត្ថុ គឺជាគោលការណ៍ណែនាំក្នុងការសម្រេចចិត្តរបស់យើង។ យើងនឹងបន្ត៖

- អភិវឌ្ឍផលិតផលហិរញ្ញវត្ថុ ដែលរួមបញ្ចូលសង្គមតាមតម្រូវការនៃគ្រួសារដែលមានចំណូលទាប។
- វិនិយោគលើហិរញ្ញវត្ថុបៃតង និងគម្រោងឆ្លើយតប ទៅនឹងការប្រែប្រួលអាកាសធាតុ។
- ប្រើប្រាស់បច្ចេកវិទ្យា ដើម្បីឈានដល់តំបន់ឆ្ងាយឱ្យបានប្រសើរជាងមុន។
- ចាប់ដៃគូយុទ្ធសាស្ត្រជាមួយដៃគូអាជីវកម្ម អង្គការអភិវឌ្ឍ និងអាជ្ញាធរមូលដ្ឋាន។

## សេចក្តីថ្លែងអំណរគុណ

ក្នុងនាមគណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អតិថិជន បុគ្គលិក ដៃគូ និងអាជ្ញាធរត្រួតពិនិត្យ សម្រាប់ការជឿជាក់ និងការគាំទ្ររបស់លោកអ្នក។ ទំនុកចិត្តរបស់លោកអ្នក គឺជាប្រភពជម្រុញចិត្ត ដែលធ្វើឲ្យយើងខ្ញុំអាចបម្រើដោយភាពឥតខ្ចោះ ភាពថ្លៃថ្នូរ និងគោលបំណង ច្បាស់លាស់។

ឈានចូលឆ្នាំ ២០២៥ យើងនឹងបន្តការប្តេជ្ញាចិត្តក្នុងការ កសាងអនាគត ដែលពលរដ្ឋកម្ពុជាគ្រប់រូបមិនគិតលើចំណូល ភេទ ឬស្ថិតក្នុងទីតាំងភូមិសាស្ត្រណាក៏ដោយ នឹងមានឱកាសរីកចម្រើន។

ដោយក្តីគោរព

<< បានចុះហត្ថលេខា >>

លោក បុល វ៉ាន់នៀត
ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ



# ២

# អំពី សហការ

# អំពីយើងខ្ញុំ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សហការ** ភីអិលស៊ី គឺជាគ្រឹះស្ថានឯកជន និងត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុន សាធារណៈទទួលខុសត្រូវមានកម្រិត (Public Limited Company) នៅក្នុងខែធ្នូ ឆ្នាំ២០១៥។ គ្រឹះស្ថានត្រូវបានបង្កើតឡើង រវាង ម្ចាស់ភាគហ៊ុនជនជាតិខ្មែរ និងជនជាតិជប៉ុន។ ក្នុងខែមេសា ឆ្នាំ២០១៦ **សហការ** បានទទួលអាជ្ញាប័ណ្ណជាផ្លូវការ ពីធនាគារជាតិនៃកម្ពុជា (NBC) ដើម្បីធ្វើប្រតិបត្តិការអាជីវកម្ម ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ប្រកបដោយនិរន្តរភាពតាមរយៈការផ្តល់ឥណទាន ដោយមានការទទួលខុសត្រូវ។

ក្នុងរយៈពេល ប្រាំបួនឆ្នាំកន្លងមក **សហការ** បានបម្រើអតិថិជនជាច្រើន និងមានចំនួនកើនឡើងជានិច្ច ទាំងនៅរាជធានីភ្នំពេញ និងបណ្តាខេត្តមួយចំនួន ដោយរួមចំណែកគាំទ្រ ដល់បរិយាបន្នហិរញ្ញវត្ថុ និងការលើកកម្ពស់ផ្នែកសេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន។ ចាប់តាំងពីចាប់ផ្តើមបង្កើតរហូតមកដល់ពេលបច្ចុប្បន្ន គ្រឹះស្ថាន បានបន្តប្តេជ្ញាចិត្តក្នុងការកែលម្អជីវភាព របស់ប្រជាជនកម្ពុជា ដោយផ្តល់ភាពងាយស្រួលក្នុងការទទួលបានសេវាឥណទាន គុណភាព និងប្រសិទ្ធិភាពនៃផលិតផលឥណទាន។

**សហការ** គោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់ និងបទបញ្ញត្តិនានា របស់រាជរដ្ឋាភិបាលកម្ពុជា និងធ្វើឲ្យស្របតាមគោលនយោបាយ និងប្រព័ន្ធច្បាប់ ដែលបានកំណត់ដោយអាជ្ញាធរពាក់ព័ន្ធ ជាពិសេស គោលនយោបាយ និងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ដើម្បីស្របទៅនឹងបទដ្ឋានអន្តរជាតិ និងបង្កើនតម្លាភាព និងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ **សហការ** បានអនុវត្តនូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ កម្ពុជា អន្តរជាតិ សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ចាប់តាំងពីឆ្នាំ២០១៩ មក។

ការអនុវត្តនេះត្រូវបានធ្វើឡើងយ៉ាងខ្ជាប់ខ្ជួន ត្រឹមត្រូវ និងត្រូវបានវាយតម្លៃ ដោយសវនករឯករាជ្យ ជារៀងរាល់ឆ្នាំ ដើម្បីធានាអនុលោមភាព និងសុចរិតភាពក្នុងរបាយការណ៍ហិរញ្ញវត្ថុ។




## ការិយាល័យកណ្តាល

អគារលេខ ប្រាំមួយ សេដេ មហាវិថី សាធារណៈរដ្ឋប៉ូឡូញ (១៦៣) សង្កាត់វាលវង់ ខណ្ឌ ប្រាំពីរមករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## សាខាស្រុកអង្គស្នួល

ផ្ទះលេខ អា សាមប្រាំពីរ ផ្លូវជាតិលេខបួន ភូមិទម្លាប់ខ្ពស់ត្បូង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ព្រះរាជាណាចក្រកម្ពុជា

- ០២៣ ៩៦៧ ៧៧៩
- sahakamfi@sahakamfi.com.kh
- ០៦១ ៥០០ ៩៧៩ / ០៩៣ ៥០០ ៩៧៩
- info@sahakamfi.com.kh
- https://www.sahakamfi.com.kh

# ចក្ខុវិស័យ បេសកកម្ម គុណតម្លៃ

## ចក្ខុវិស័យ

" ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេ ក្នុងការលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់សិទ្ធអំណាចផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍធនធានមនុស្ស ដោយការផ្តល់សេវាហិរញ្ញវត្ថុ ប្រកបដោយការទទួលខុសត្រូវ ការអប់រំ និងការប្តេជ្ញាចិត្តដ៏មាំមួនចំពោះសុចរិតភាពក្នុងអង្គភាព។ "

## បេសកកម្ម

" បេសកកម្មរបស់យើង គឺផ្តល់សេវាហិរញ្ញវត្ថុ ដែលមានតម្លៃសមរម្យ និងមានទំនួលខុសត្រូវដល់ប្រជាជន ដែលមិនទាន់មានឱកាសទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា ដើម្បីជួយឲ្យបុគ្គល និងគ្រួសារ បង្កើនចំណូល បង្កើតនិរន្តរភាពនៃជីវភាព និងកែលម្អស្តង់ដាជីវិតរបស់ពួកគេ។ "

## ពាក្យស្លោក

"រួមគ្នាដើម្បីភាពចម្រើន!"

## គុណតម្លៃ

### ១. សុចរិតភាព និងតម្លាភាព

" យើងគោរពតាមស្តង់ដាខ្ពស់បំផុត នៃភាពស្មោះត្រង់ ការទទួលខុសត្រូវ និងឆន្ទៈលើការប្រព្រឹត្តតាម សីលធម៌ ក្នុងគ្រប់ប្រតិបត្តិការរបស់យើង ដើម្បីធានានូវទំនុកចិត្តពីអតិថិជន អាជ្ញាធរ និងដៃគូ។"

### ២. ការយកអតិថិជនជាមូលដ្ឋាន

" យើងប្តេជ្ញាចិត្តចំពោះការយល់ដឹង និងបម្រើតាមតម្រូវការពិសេសរបស់អតិថិជន ជាមួយការគោរព ការយល់ដឹងពីអតិថិជន និងការថែទាំជាពិសេសសម្រាប់អតិថិជន នៅក្នុងតំបន់ជនបទ និងតំបន់ដែលមិនទាន់មានការចូលដល់បានគ្រប់គ្រាន់នៃសេវាហិរញ្ញវត្ថុ។ "

### ៣. បរិយាបន្នហិរញ្ញវត្ថុ និងការផ្តល់សិទ្ធិអំណាច

" យើងខិតខំផ្តល់ឱ្យប្រជាជនកម្ពុជាទាំងអស់ អាចទទួលបានសេវាហិរញ្ញវត្ថុ ដើម្បីជួយឱ្យពួកគេ (បុគ្គល និងគ្រួសារ) មានជីវភាពល្អប្រសើរជាមួយឱកាសទទួលបានឥណទាន ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងឱកាស។ "

### ៤. និរន្តរភាព និងផលប៉ះពាល់សង្គម

" យើងប្តេជ្ញាចិត្ត ក្នុងការបង្កើតតម្លៃយូរអង្វែងសម្រាប់សហគមន៍ តាមរយៈការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ការសម្របខ្លួនទៅនឹងសេដ្ឋកិច្ច និងការរួមចំណែកការពារនិរន្តភាពបរិស្ថាន។"

### ៥. នវានុវត្តន៍

" យើងទទួលយកនូវការច្នៃប្រឌិតថ្មីៗ ដើម្បីបម្រើអតិថិជនឱ្យកាន់តែប្រសើរឡើង និងឆ្លើយតបទៅនឹងបរិបទហិរញ្ញវត្ថុ ដែលកំពុងផ្លាស់ប្តូរ។"

# ផលិតផលរបស់យើង៖

## ឥណទានអាជីវកម្ម

ឥណទានអាជីវកម្ម គឺជាឥណទានដែលបង្កើតឡើងសម្រាប់បុគ្គល អ្នកធ្វើអាជីវកម្មឯកជន ឬដៃគូអាជីវកម្ម ដើម្បីគាំទ្រ ឬពង្រីកសកម្មភាពអាជីវកម្មបង្កើនប្រាក់ចំណូល ជាពិសេស ផ្តោតលើអាជីវកម្មខ្នាតតូច និងមធ្យម។ ក្នុងនោះរួមមាន ការផ្តល់ឥណទាន សម្រាប់ដំណើរ ការទ្រព្យសកម្ម ការទិញឧបករណ៍ ឬសារពើភណ្ឌ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មឬការចំណាយប្រតិបត្តិផ្សេងៗ។





## ឥណទានយានជំនិះ

ឥណទានយានជំនិះ គឺជាឥណទានសម្រាប់បំពេញតម្រូវការ របស់អតិថិជនជាបុគ្គល ឬអាជីវកម្ម ក្នុងការទិញយានយន្តថ្មី ឬយានយន្តដែលបានប្រើប្រាស់រួច ដូចជា ម៉ូតូ ឬរថយន្ត សម្រាប់ប្រើ ប្រាស់ផ្ទាល់ខ្លួន ឬអាជីវកម្ម។

## ឥណទានលំនៅដ្ឋាន

ឥណទានលំនៅដ្ឋាន គឺជាឥណទានសម្រាប់បុគ្គល ឬគ្រួសារ សម្រាប់សាងសង់ ទិញជួសជុលកែលម្អរ ឬពង្រីកអចលនទ្រព្យស្នាក់នៅ ដើម្បីបង្កើនគុណភាពជីវិត។





## ឥណទានផ្ទាល់ខ្លួន

ឥណទានផ្ទាល់ខ្លួន គឺជាឥណទានសម្រាប់បុគ្គល ដែលមិនទាក់ទងនឹងអាជីវកម្ម ឬលំនៅដ្ឋាន។ វាត្រូវបានបង្កើតឡើង ដើម្បីគាំទ្រលើចំណាយផ្ទាល់ខ្លួន ឬគ្រួសារ ដូចជា ចំណាយពាក់ព័ន្ធ នឹងការសិក្សា ការព្យាបាលជំងឺ ឬសុខភាព ការចំណាយប្រើប្រាស់ប្រចាំគ្រួសារ ការទិញ ឧបករណ៍ កាតព្វកិច្ចគ្រួសារ ឬសង្គម និងចំណាយបន្ទាន់ផ្សេងៗ។

# សមត្ថផលសម្រេចបានសំខាន់ៗ

**ឆ្នាំ ២០១៦**

ទទួលបានអាជ្ញាបណ្ណ ប្រតិបត្តិអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(MFI) ពីធនាគារជាតិ នៃកម្ពុជានៅខែមេសា ជាមួយនឹងដើមទុន ចុះបញ្ជីសរុបចំនួន ៣០០,០០០ដុល្លារអាមេរិក។

**ឆ្នាំ ២០១៧**

បង្កើនដើមទុនចុះបញ្ជីសរុបរហូតដល់ ១,៨០០,០០០ ដុល្លារអាមេរិក ដើម្បីបង្កើនស្ថិរភាពហិរញ្ញវត្ថុ នៃស្ថាប័ន និងគាំទ្រការរីកលូតលាស់នាពេលអនាគត។

**ឆ្នាំ ២០១៩**

បង្កើនដើមទុនចុះបញ្ជីសរុប រហូតដល់ ២,៣០០,០០០ ដុល្លារអាមេរិក ដើម្បីពង្រឹងសមត្ថភាពក្នុងការគាំទ្រការ រីកលូតលាស់ប្រកបដោយនិរន្តរភាព។ ចំនួនអតិថិជនបានកើនដល់ ៧៩១នាក់ ក្នុងពេលដែលផលប័ត្រ ឥណទាន សរុបកើនដល់ ៣.៣៤ លានដុល្លារអាមេរិក ឆ្លុះបង្ហាញពីការរីកលូតលាស់ នៃតំបន់ប្រតិបត្តិការ និងការទុកចិត្តជាបន្តបន្ទាប់ ពីសហគមន៍ដែលយើងបម្រើ។ ដើម្បីអនុលោមតាមបទប្បញ្ញត្តិ និងអនុវត្តន៍ជាអន្តរជាតិ យើងបានអនុវត្ត នូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ កម្ពុជា អន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ។

**ឆ្នាំ ២០២០**

បង្កើនដើមទុនចុះបញ្ជីសរុបរហូតដល់ ៣,៣០០,០០០ ដុល្លារអាមេរិក ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រការលូត លាស់នាពេលអនាគត។

**ឆ្នាំ ២០២១**

ទទួលបានអាជ្ញាបណ្ណពីធនាគារជាតិ នៃកម្ពុជា ដើម្បីបើកសាខាអង្គស្នូល និងពង្រីកសេវាកម្មបន្ថែម។ យើងមាន អតិថិជនសកម្មចំនួន ៤៣៤នាក់ ជាមួយនឹងផលបត្រឥណទានសរុបចំនួន ៧.៣៧ លាន ដុល្លារអាមេរិក។ ដើម្បី ឆ្លើយតបទៅនឹងផលប៉ះពាល់ ពីវីរុសកូវីដ-១៩ យើងបានផ្តល់ជម្រើស ចំណាត់ថ្នាក់សំណងឥណទានទៅអតិថិជន ដែលរងផលប៉ះពាល់ខណៈដែលបន្តផ្តល់ជំនួយហិរញ្ញវត្ថុ។ ដូចគ្នានេះផងដែរ យើងបានថែរក្សាវិធាន គ្រប់គ្រងហានិភ័យយ៉ាងម៉ឺងម៉ាត់ ដើម្បីការពារគុណភាពនៃផលបត្រឥណទាន និងស្ថិរភាពស្ថាប័ន។

**ឆ្នាំ ២០២៣**

បង្កើនដើមទុនចុះបញ្ជីសរុបរហូតដល់ ៣,៦០០,០០០ដុល្លារអាមេរិកដើម្បីបង្កើននិរន្តរភាពនៃការលូតលាស់។ យើងបានសម្រេចដល់អតិថិជនសកម្ម ចំនួន៨៦៣នាក់ ជាមួយផលបត្រឥណទាន សរុបកើនដល់ ៩.៤៨ លានដុល្លារអាមេរិក។ យើងបានដាក់ដំណើរការប្រព័ន្ធ Core Banking ថ្មី ដើម្បីបង្កើនប្រសិទ្ធភាពសេវាកម្ម និងប្រតិបត្តិការប្រចាំថ្ងៃ។ លើសពីនេះ យើងបានផ្លាស់ទីការិយាល័យកណ្តាល ទៅអគារ 6CD មហាវិថី សាធារណៈរដ្ឋ ប៉ុន្មាញ 163 សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តនៃការអភិវឌ្ឍស្ថាប័ន និងបង្កើនភាពងាយស្រួលក្នុងការទទួលនូវសេវាកម្ម។

**ឆ្នាំ ២០២៤**

រក្សាអតិថិជន និងការលូតលាស់ផលបត្រឥណទាន ជាមួយគ្នានេះបានធ្វើការពិនិត្យឡើងវិញនូវ យុទ្ធសាស្ត្រដើម្បីវាយតម្លៃទិសដៅ រយៈពេលវែងរបស់យើង។ យើងបានធ្វើបច្ចុប្បន្នភាពចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្នូល ដើម្បីបង្ហាញយ៉ាងត្រឹមត្រូវ នូវគោលដៅកំពុងអភិវឌ្ឍរបស់យើង និងបញ្ជាក់ការប្តេជ្ញាចិត្ត ចំពោះការលូតលាស់ដ៏មានចីរភាព និងការរួមបញ្ចូលសម្រាប់សហគមន៍ដែលយើងបម្រើ។

# វិលេចប្រតិបត្តិការសំខាន់ៗ

| ឆ្នាំប្រតិបត្តិបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ | ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| តំបន់គោលដៅថ្នាក់ខេត្ត | ១២ | ១២ | ១៣ |
| តំបន់គោលដៅថ្នាក់ស្រុក | ៥៣ | ៥៧ | ៤៧ |
| តំបន់គោលដៅថ្នាក់ឃុំ | ១៧០ | ១៨២ | ១៥២ |
| តំបន់គោលដៅថ្នាក់ភូមិ | ៤៦០ | ៤៨៥ | ៣៦០ |
| ចំនួនសាខាសរុប | ២ | ២ | ២ |
| ចំនួនបុគ្គលិកសរុប | ៤២ | ៣៩ | ៤០ |
| ចំនួនអតិថិជនសរុប | ៨២៨ | ៨២៦ | ៥៩០ |
| ផលបត្រឥណទានសរុប | ៨,៩១៧,៤៥៩ | ៩,៧២៧,៦៦៥ | ៨,៤៨៧,០៩៣ |
| ផលបត្រឥណទានសរុបក្នុងមន្ត្រីឥណទានម្នាក់ | ៦៨៥,៩៥៨ | ១,៣៨៩,៦៦៦ | ១,២១២,៤៤២ |
| ផលបត្រឥណទានសរុបក្នុងបុគ្គលិកម្នាក់ | ២១២,៣២០ | ២៤៩,៤២៧ | ២១២,១៧៧ |
| ទំហំឥណទានជាមធ្យម (ដុល្លារ) | ១០,៧៦៩.៨៨ | ១១,៧៧៧ | ១៤,៣៨៥ |



# វិលេចព័ត៌មានហិរញ្ញវត្ថុសំខាន់ៗ

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| ទ្រព្យសរុប | ៤១,៥៧៤,២៧៩ | ៤១,៩២៨,២៥១ | ៣៩,៤២០,០៩០ |
| បំណុលសរុប | ៣៤,៨២៩,២២០ | ៣៤,៣៥៦,៩០១ | ៣២,០៨២,០៥២ |
| មូលធនសរុប | ៦,៧៤៥,០៦៩ | ៧,៥៧១,៣៥០ | ៧,៣៣៨,០៣៨ |
| | | | |
| **ប្រាក់ចំណេញ/ខាត (គិតជាលានរៀល)** | | | |
| ចំណូលសរុប | ៦,៤៣៩,៧៣៦ | ៦,៤៨១,៦៩២ | ៥,៣០១,១៨៦ |
| ប្រាក់ចំណេញ/ខាតមុនចំណាយពន្ធ | (៣១២,១០៨) | ៣១០,១០១ | ២,៤៦៩,២០៦ |
| ប្រាក់ចំណេញ/ខាតបន្ទាប់ពីចំណាយពន្ធ | (៧២៣,២៥៩) | ២៩២,១២៨ | ១,៨៣៥,៨០៧ |
| ចំណូលបូកសរុប | (៨២៦,២៩១) | ២៣៣,៣១២ | ១,៨៩៣,៧១០ |
| | | | |
| **អនុបាតហិរញ្ញវត្ថុ** | | | |
| អនុបាតសោធនភាព | ១៦.៣៣% | ១៨.០៦% | ១៦.៥៦% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥១៦.៣៧% | ៤៥៣.៧៨% | ៤៣៧.២០% |
| អនុបាតឥណទានមិនដំណើរការ | ១៨.០៦% | ៦.៣៥% | ២.៤៧% |
| អត្រាឆ្លើយតបលើទ្រព្យសរុប | -១.៧៤% | ០.៦៩% | ០.៦៩% |
| អត្រាឆ្លើយតបលើទុន | -១១.២៣% | ៣.៨៣% | ៤.១៩% |



# សក្ខីភាពពីអតិថិជន




**អ្នកស្រី អេង សុខុន – ភូមិមហារអំពែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ**

**អ្នកស្រី អេង សុខុន** ជាសហគ្រិនស្ត្រី ដែលមានការប្តេជ្ញាចិត្តខ្ពស់។ អ្នកស្រីបានចាប់ផ្តើមអាជីវកម្មលក់កាហ្វេ និងឥវ៉ាន់ចាប់ហួយតូចមួយនៅនឹងផ្ទះក្នុងស្រុកកំណើតរបស់អ្នកស្រី តាំងពីឆ្នាំ ២០១៤។ ដោយមើលឃើញពីតម្រូវការប្រើប្រាស់របស់អតិថិជនមានការកើនឡើង អ្នកស្រីក៏សម្រេចចិត្តពង្រីកអាជីវកម្មរបស់អ្នកស្រី ទៅជាអ្នកលក់បោះដុំក្នុងតំបន់ បន្ថែមលើការលក់រាយរបស់គាត់។

ការពង្រីកអាជីវកម្មរបស់អ្នកស្រី ពិតជាត្រូវការដើមទុនច្រើនសមរម្យ ហេតុដូច្នេះអ្នកស្រីក៏សម្រេចចិត្តដាក់ពាក្យស្នើកម្ចី មកកាន់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សហការ** ដើម្បីពង្រីកដើមទុនអាជីវកម្មរបស់គាត់ ។ បច្ចុប្បន្នអាជីវកម្មរបស់អ្នកស្រីកំពុងមានដំណើរការល្អ និងមានអតិថិជនកើនឡើងច្រើនជាងពីមុនជាលំដាប់។

**"តាមរយៈការគ្រប់គ្រងប្រាក់ចំណូលប្រកបដោយវិន័យ និងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពី សហការ បានធ្វើអោយអាជីវកម្មរបស់ខ្ញុំរីកចម្រើន និងបានធ្វើឲ្យក្តីសុបិន្តរបស់ខ្ញុំក្លាយជាការពិត។"** នេះជាការចែករំលែក ដោយមោទនភាពរបស់អ្នកស្រី ។



លោក ឈួប សុខហួរ – ភូមិកុកសតិន ស្រុកសាមគ្គីមនិជ័យ ខេត្តកំពង់ស្ពឺ

នៅឆ្នាំ ២០១៨ **លោក ឈួប សុខហួរ** បានចាប់ផ្តើមអាជីវកម្មលក់សម្ភារៈអគ្គិសនី និងសម្ភារៈសំណង់នៅជិតផ្សារមូលដ្ឋាន ក្នុងភូមិរបស់លោក។ ពេលដែលតម្រូវការពីអតិថិជនកើនឡើង លោកបានប្រឈមនឹងបញ្ហា ផ្គត់ផ្គង់ទំនិញឲ្យបានគ្រប់គ្រាន់ សម្រាប់បំពេញតម្រូវការរបស់អតិថិជន។

ដោយទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពី **សហគ្រាស** លោកអាចពង្រីកមុខទំនិញរបស់ខ្លួន បង្កើនការបញ្ជាទិញ និងពង្រីកអាជីវកម្ម បានដោយជោគជ័យ។ សព្វថ្ងៃ លោកកំពុងដំណើរការហាងលក់សម្ភារៈយ៉ាងជោគជ័យ និងគួរឱ្យទុកចិត្តសម្រាប់អតិថិជនក្នុងតំបន់។

**"សូមអរគុណចំពោះការគាំទ្រពី សហគ្រាស ដែលបានជួយឱ្យខ្ញុំ អាចពង្រីកអាជីវកម្ម និងបម្រើសហគមន៍របស់ខ្ញុំបាន ប្រសើរឡើង"**
លោកបានចែករំលែកប្រកបដោយមោទនភាព។



# ៣

# អភិបាលកិច្ចសាជីវកម្ម

# សារពីអភិបាលសាជីវកម្ម

នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សហការ** ភីអិលស៊ី យើងជឿជាក់យ៉ាងមុតមាំថា អភិបាលសាជីវកម្មដ៏រឹងមាំ គឺជាចំណុចសំខាន់ សម្រាប់ការលូតលាស់ប្រកបដោយចីរភាព និងភាពល្អឯករបស់ស្ថាប័ន។ ក្នុងឆ្នាំ ២០២៤ យើងបានបន្តពង្រឹង ប្រព័ន្ធអភិបាលសាជីវកម្មរបស់យើង ដើម្បីធានាថាប្រព័ន្ធនោះមានប្រសិទ្ធភាពមានតម្លាភាព ហើយស្របតាមស្តង់ដារ បទបញ្ញត្តិ និងតម្រូវការរីកចម្រើនរបស់ភាគីពាក់ព័ន្ធទាំងឡាយ។

ក្រុមប្រឹក្សាភិបាលរបស់យើង មានសារៈសំខាន់ ក្នុងការផ្តល់ជាយុទ្ធសាស្ត្រណែនាំការគ្រប់គ្រងហានិភ័យ និងថែរក្សាស្តង់ដារ នៃការទទួលខុសត្រូវខ្ពស់ និងក្រមសីលធម៌។ តាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងការសម្រេចចិត្តដ៏ត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលធានាថា សកម្មភាពប្រតិបត្តិរបស់យើងនៅតែស្របទៅតាមបេសកកម្មរបស់ **សហការ** ក្នុងការលើកកម្ពស់សហគមន៍តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកមដោយទំនួលខុសត្រូវ។

យើងបានទទួលផលពីវប្បធម៌ដ៏រឹងមាំ ដោយផ្អែកលើសុចរិតភាព ភាពស្មើគ្នា និងវិជ្ជាជីវៈ។ តាមរយៈការគ្រប់គ្រងផ្ទៃក្នុង ដែលបានកំណត់យ៉ាងច្បាស់ និងវិធានលម្អិត នៃការអនុលោមតាមបទបញ្ញត្តិ និងប្រព័ន្ធត្រួតពិនិត្យលទ្ធផលការងារយ៉ាងរឹងមាំ យើងមិនត្រឹមតែបង្កើនប្រសិទ្ធភាពប្រតិបត្តិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនទំនុកចិត្ត ពីអតិថិជន ដៃគូ និងបញ្ញត្តិករផងដែរ។

នាពេលអនាគត **សហការ** នឹងបន្តការកែលម្អ នូវការអនុវត្តន៍អភិបាលសាជីវកម្មរបស់ខ្លួន ដើម្បីគាំទ្រដល់ការបង្កើតតម្លៃយូរអង្វែង រក្សាទំនុកចិត្តរបស់ភាគីពាក់ព័ន្ធ និងចូលរួមប្រកបដោយអត្ថន័យ ក្នុងការជម្រុញឱ្យមាននូវបរិយាបណ្ណហិរញ្ញវត្ថុ និងស្ថិរភាពសេដ្ឋកិច្ចនៅកម្ពុជា។



# ក្រុមប្រឹក្សាភិបាល



## លោក បុល វ៉ាន់នៀត

ប្រធានក្រុមប្រឹក្សាភិបាល
និងប្រធាននាយកប្រតិបត្តិ

**លោក បុល វ៉ាន់នៀត** ត្រូវបានតែងតាំង ជាសមាជិក និងជាប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងខែធ្នូ ឆ្នាំ២០១៥ និងត្រូវបានតែងតាំង ជាតំណាង នៃស្ថាប័នមីក្រូហិរញ្ញវត្ថុ សាហាការ ភីអិលស៊ី នៅក្នុងខែមករា ឆ្នាំ ២០១៦។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកភាសាជប៉ុន នៅវិទ្យាស្ថានភាសាបរទេស នៃសកលវិទ្យាល័យ ភូមិន្ទភ្នំពេញក្នុងឆ្នាំ២០១១។

លោកមានបទពិសោធន៍ការងារ ច្រើនជាង ១០ឆ្នាំ ក្នុងវិស័យធនាគារ និងវិស័យអប់រំ។



## លោក តាកាហ៊ីរ៉ូ យ៉ាម៉ាស៊ីតា

អភិបាល
និងប្រធាននាយកហិរញ្ញវត្ថុ

**លោក តាកាហ៊ីរ៉ូ យ៉ាម៉ាស៊ីតា** ត្រូវបានតែងតាំង ជាសមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងខែធ្នូ ឆ្នាំ ២០១៥ ហើយត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ (CFO) នៅក្នុង ខែតុលា ឆ្នាំ ២០១៦។

លោកបានបញ្ចប់បរិញ្ញាបត្រ ផ្នែកសេដ្ឋកិច្ច ក្នុងឆ្នាំ ១៩៩៩ ពីសាកលវិទ្យាល័យ កាន់សាយ (Kansai University) និងបានបញ្ចប់សញ្ញាបត្របច្ចេកទេសខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ក្នុងឆ្នាំ ២០០៦ ពីសាកលវិទ្យាល័យ វ៉ែល ព្រីហ្វីកូល ស៊ីមរុ (University of Wales Prifysgol Cymru)។

លោកមានបទពិសោធន៍ធ្វើការច្រើនជាង ២០ឆ្នាំ ក្នុងវិស័យធនាគារ និងវិស័យអប់រំនៅក្នុងប្រទេសជប៉ុន ។



## លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអឺឈិ

ក្រុមប្រឹក្សាភិបាលឯករាជ្យ

**លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអឺឈិ** ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ក្នុងខែមិថុនា ឆ្នាំ២០១៩ និងបានទទួលការ អនុម័តពីធនាគារជាតិនៃកម្ពុជា ក្នុងខែតុលា ឆ្នាំ២០១៩។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិស្វកម្ម ក្នុងឆ្នាំ១៩៧៦ ពី សាកលវិទ្យាល័យកាណាកាវ៉ា (Kanagawa University)។

លោកមានបទពិសោធន៍ ការងារច្រើនជាង ៣០ ឆ្នាំ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ នៅប្រទេសជប៉ុន ក្នុងស្ថាប័នគ្រប់គ្រង ទ្រព្យសម្បត្តិឯកជន និងក្រុមហ៊ុន វិនិយោគ។ បន្ថែមពីនេះ លោកក៏ជាប្រធាននាយកប្រតិបត្តិ នៃក្រុមហ៊ុន មីយ៉ាអឺឈិ អេឡិចត្រូនិក អិនជីនៀរីង ខូអិលធីឌី (Miyauchi Electric Engineering Co., LTD)។

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| កាលបរិច្ឆេទ | វិធីសាស្ត្រនៃកិច្ចប្រជុំ | ក្រុមប្រឹក្សាភិបាលដែលចូលរួមប្រជុំ |
|---|---|---|
| ៦ មករា ២០២៤ | កិច្ចប្រជុំកូនកាត់ (Hybrid Meeting)<br>(ចូលរួមផ្ទាល់ជាបុគ្គល<br>និងតាមវីដេអូផ្សាយផ្ទាល់) | លោក បុល វ៉ាន់នៀត<br>លោក តាកាហ៊ីរ៉ូ យ៉ាម៉ាស៊ីតា<br>លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអឺឈិ |
| ៥ សីហា ២០២៤ | កិច្ចប្រជុំកូនកាត់ (Hybrid Meeting)<br>(ចូលរួមផ្ទាល់ជាបុគ្គល<br>និងតាមវីដេអូផ្សាយផ្ទាល់) | លោក បុល វ៉ាន់នៀត<br>លោក តាកាហ៊ីរ៉ូ យ៉ាម៉ាស៊ីតា<br>លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអឺឈិ |



# គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

## គណៈកម្មាធិការប្រឈមនឹងហានិភ័យ និងប្រតិបត្តិតាម (BRCC)

នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាហកា ភីអិលស៊ី ក្រុមប្រឹក្សាភិបាល និងគណៈនាយកប្រតិបត្តិ យល់ច្បាស់ថា ការគ្រប់គ្រងហានិភ័យដ៏រឹងមាំគឺជាគ្រឹះសំខាន់សម្រាប់ភាពជោគជ័យអាជីវកម្ម ប្រកបដោយចីរភាព។ យើងបានប្តេជ្ញាដើម្បីសម្រេចបាន នូវគោលបំណងជាយុទ្ធសាស្ត្រ និងអាជីវកម្មរបស់យើង ក្នុងក្របខណ្ឌ នៃការទទួលយកហានិភ័យដែលបានកំណត់។ ក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចក្នុង ការកំណត់កម្រិតទទួលយក នូវហានិភ័យ និងធានាការគ្រប់គ្រងហានិភ័យត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព ទូទាំងស្ថាប័ន។

គណៈកម្មាធិការប្រឈមនឹងហានិភ័យ និងប្រតិបត្តិតាម (BRCC) ដើរតួនាទីជាអ្នកទទួលប្រតិភូកម្ម ពីក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យ និងពិនិត្យឡើងវិញនូវទិដ្ឋភាពហានិភ័យទាំងមូលរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាហការ។ កិច្ចការនេះរួមមាន ប៉ុន្តែមិនបានកំណត់ត្រឹមតែនូវការត្រួតពិនិត្យ ហានិភ័យយុទ្ធសាស្ត្រ និងអាជីវកម្ម គុណភាព និងការផ្តោតលើផលបត្រឥណទាន ការធានាទុនគ្រប់គ្រាន់ និងការធ្វើផែនការមូលធន និងសាច់ប្រាក់ងាយស្រួល ហានិភ័យលើប្រតិបត្តិការនិងបច្ចេកវិទ្យា ការព្រួយបារម្ភពីកេរ្តិ៍ឈ្មោះគ្រឹះស្ថាន និងហានិភ័យពាក់ព័ន្ធនឹងការប្រតិបត្តិតាម ជាពិសេស ការប្រតិបត្តិតាមច្បាប់ចំពោះការប្រឆាំងលាងសម្អាតសាច់ប្រាក់/ការប្រឆាំងកលការផ្តល់ហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងនៃការផ្តល់ហិរញ្ញប្បទាន ដល់ការរីកសាយភាយនៃអាវុធមហាប្រល័យ (AML/CFT/CPF)។

BRCC ក៏មានតួនាទីសំខាន់ ក្នុងការវាយតម្លៃលើកម្រិតទទួលខុសត្រូវ នៃហានិភ័យជារួមរបស់ សហការ និងផ្តល់ជាអនុសាសន៍ទៅកាន់ ក្រុមប្រឹក្សាភិបាល។ ភារៈកិច្ចនេះ ក៏រួមបញ្ចូលនូវការវាយតម្លៃលើភាពសមរម្យ និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង របស់គ្រឹះស្ថាន ព្រមទាំងការពិចារណាលើឥទ្ធិពលនៃការ ផ្លាស់ប្តូរបញ្ញតិសំខាន់ៗ និងផលប៉ះពាល់ដល់យុទ្ធសាស្ត្រនៃការលូតលាស់របស់ **សហការ** នៅក្នុងបរិបទឥណទានដ៏លូតលាស់ និងប្រកួតប្រជែង។

## គណៈកម្មាធិការសវនកម្ម (AUDC)

គណៈកម្មាធិការសវនកម្មមានតួនាទីសំខាន់ក្នុងការការពារ សុចរិតភាព តម្លាភាព និងទំនួលខុសត្រូវខ្ពស់ នៃការរាយការណ៍ហិរញ្ញវត្ថុ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាហការ។ ដោយការទទួលបាននូវប្រតិភូកម្មអំណាចពីក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនេះមានភារកិច្ចត្រួតពិនិត្យលើ ដំណើរការរាយការណ៍ហិរញ្ញវត្ថុ ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង លទ្ធិផលនៃមុខងាររបស់សវនករផ្ទៃក្នុង និងសវនករខាងក្រៅ ព្រមទាំងការប្រតិបត្តិទៅតាមច្បាប់ បានបញ្ញត្តិ ។

គណៈកម្មាធិការនេះធានាថា របាយការណ៍ហិរញ្ញវត្ថុ បង្ហាញឱ្យឃើញពីស្ថានភាពហិរញ្ញវត្ថុជាក់ស្តែង និងត្រឹមត្រូវរបស់គ្រឹះស្ថាន ហើយត្រូវបានរៀបចំស្របតាមស្តង់ដាកម្ពុជាអន្តរជាតិ ក្នុងការរាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា (CIFRS for SME)។

គណៈកម្មាធិការនេះ ក៏ពិនិត្យលើលទ្ធផលសវនកម្ម ការឆ្លើយតបពីគណៈគ្រប់គ្រង និងការអនុវត្តន៍នូវសកម្មភាពកែតម្រូវ ជាពិសេសផ្តោតលើការសង្កេតពីសវនកម្មផ្ទៃក្នុង និងការប្រតិបត្តិតាមបទប្បញ្ញត្តិ។ តាមរយៈការត្រួតពិនិត្យជាប្រចាំ និងការជួបប្រជុំជាទៀងទាត់ជាមួយគណៈគ្រប់គ្រង សវនករផ្ទៃក្នុង និង សវនករឯករាជ្យ គណៈកម្មាធិការសវនកម្ម គាំទ្រដល់ក្រុមប្រឹក្សាភិបាលក្នុងការធានាបាននូវអនុវត្តន៍ អភិបាលកិច្ចល្អ និងរក្សាទុកទំនុកចិត្តរបស់ភាគីពាក់ព័ន្ធ ចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ របស់សាហការ។



# គណៈកម្មាធិការនាយកប្រតិបត្តិ (EXCOM)

គណៈកម្មាធិការនាយកប្រតិបត្តិ ត្រូវបានផ្តល់កាតព្វកិច្ច ក្នុងការប្រតិបត្តិ និងជម្រុញការអនុវត្តន៍យុទ្ធសាស្ត្រ និងប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សហការ**។

គណៈកម្មាធិការនេះមានសមាសភាពពីសមាជិក ក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់ និងដឹកនាំដោយប្រធាននាយកប្រតិបត្តិ (CEO) ដែលជាអ្នកដឹកនាំក្នុងការគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ និងធានាបាននូវការអនុវត្តសម្រេចបាននូវទស្សនវិស័យ និងគោលដៅរយៈវែងរបស់គ្រឹះស្ថាន។

EXCOM ជួបប្រជុំជាប្រចាំដើម្បីពិនិត្យលើសូចនាករ សមិទ្ធផលសំខាន់ៗ តាមដានលទ្ធផលអាជីវកម្ម វាយតម្លៃលើហានិភ័យ និងត្រួតពិនិត្យការអនុវត្តន៍យុទ្ធសាស្ត្រអាជីវកម្ម ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

គណៈកម្មាធិការនេះក៏មានតួនាទីសំខាន់ក្នុងការធានានូវការប្រតិបត្តិតាមបទប្បញ្ញត្តិ បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងឆ្លើយតបយ៉ាងសកម្មចំពោះបញ្ហាថ្មីៗ និងឱកាសក្នុងទីផ្សារ។

តាមរយៈជំនាញប្រមូលផ្តុំ និងកិច្ចសហការជិតស្និទ្ធ រវាងនាយកដ្ឋានផ្សេងៗ គណៈកម្មាធិការនាយកប្រតិបត្តិ ធានាថា សាហការ នៅតែមានល្បឿន មានភាពធន់ និងផ្តោតលើការផ្តល់តម្លៃចីរភាពដល់ភាគីពាក់ព័ន្ធ ព្រមទាំងរក្សានូវការប្តេជ្ញាចិត្តខ្ពស់ ចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច ។



# រចនាសម្ព័ន្ធគ្រប់គ្រង




49€/Kg

# ៤

# ការគ្រប់គ្រងហានិភ័យ
# និងការប្រតិបត្តិតាម

# ការគ្រប់គ្រងហានិភ័យ

ក្នុងឆ្នាំ ២០២៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សហការ** បានបន្តពង្រឹងការប្តេជ្ញារបស់ខ្លួនក្នុងការប្រមូលនូវផល នៃវប្បធម៌គ្រប់គ្រងហានិភ័យយ៉ាងរឹងមាំទូទាំងគ្រឹះស្ថាន។

ការខិតខំប្រឹងប្រែងនេះផ្អែកលើការ អនុវត្តន៍ជាបន្តបន្ទាប់ នៃស៊ុមគ្រប់គ្រងហានិភ័យរួម (SRMF) ដែលត្រូវបានអនុវត្តន៍ ក្នុងការប្រតិបត្តិអាជីវកម្មជួរមុខ និងមុខងារផ្សេងៗ ។

ស៊ុម SRMF ត្រូវបានរៀបចំឡើងដើម្បីផ្តល់ជារចនាសម្ព័ន្ធ និងវិធីសាស្រ្ត ដើម្បីកំណត់ សិក្សា គ្រប់គ្រង និងត្រួតពិនិត្យហានិភ័យ។ វាត្រូវបានពិនិត្យជានិរន្ត និងធ្វើការកែលម្អ ដើម្បីធានាភាពសមស្របទៅនឹង ទិដ្ឋភាពហានិភ័យរបស់សហការ ដែលកំពុងអភិវឌ្ឍ និងអាចមានផលប៉ះពាល់ផ្សេងៗក្នុងទីផ្សារការរំពឹងរបស់ធនាគារជាតិ និងលក្ខណៈល្អបំផុតក្នុងឧស្សាហកម្ម។

នៅចំណុចស្នូលនៃវប្បធម៌គ្រប់គ្រងហានិភ័យរបស់សហការ គឺមានពន្លឺច្បាស់ចេញពីថ្នាក់ដឹកនាំ ("tone from the top") ដែលជាវិធីសាស្រ្តប្រកបដោយភាពជាអ្នកដឹកនាំ ផ្តោតលើសារៈសំខាន់ នៃការគ្រប់គ្រងហានិភ័យនៅគ្រប់កម្រិតនៃអង្គភាព។ វប្បធម៌នេះជម្រុញឱ្យមាន ការទទួលខុសត្រូវរួមគ្នា ដែលការយល់ដឹងអំពីហានិភ័យ និងការធ្វើសេចក្តីសម្រេចចិត្ត ដោយប្រុងប្រយ័ត្នពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃ និងការធ្វើផែនការយុទ្ធសាស្រ្ត។

**សហការ** មានជំនឿថា ការគ្រប់គ្រងហានិភ័យ យ៉ាងមានប្រសិទ្ធភាពមិនមែនជាការទទួលខុស ត្រូវរបស់ នាយកដ្ឋានណាតែមួយនោះទេ ប៉ុន្តែជាកាតព្វកិច្ចរួមរបស់និយោជិតទាំងអស់។ គោលការណ៍នេះត្រូវបាន អនុវត្តតាមរយៈរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យដ៏ច្បាស់លាស់ ដែលធានានូវការគ្រប់គ្រងភាពច្បាស់លាស់នៃតួនាទី និងភារកិច្ច និងការអប់រំអំពីហានិភ័យ និងការទំនាក់ទំនងជាប្រចាំទូទាំងសគ្រឹះស្ថាន។

## ខ្សែបន្ទាត់ការពារទាំងបី

**ប្រតិបត្តិការជួរមុខ**
ដោះស្រាយដោយផ្ទាល់ជាមួយនឹងហានិភ័យក្នុងសកម្មភាពប្រចាំថ្ងៃ ការកំណត់អត្តសញ្ញាណការវាយតម្លៃ និងកាត់បន្ថយហានិភ័យនៅក្នុងតំបន់របស់ពួកគេ។




**ការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម**
បង្កើតគោលនយោបាយ តាមដានហានិភ័យ និងធានាការប្រកាន់ខ្ជាប់បទប្បញ្ញត្តិ និងការត្រួតពិនិត្យផ្ទៃក្នុង។

**សវនកម្មផ្ទៃក្នុង**
ផ្តល់ការធានា និងការវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងដំណើរការត្រួតពិនិត្យ។

# ការប្រតិបត្តិទៅតាមបទប្បញ្ញត្តិ និងការរាយការណ៍របាយការណ៍ហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ប្រតិបត្តិដោយមានការប្តេជ្ញា ក្នុងការអនុវត្ត ទៅតាមបទប្បញ្ញត្តិ និងភាពសុចរិតផ្នែកហិរញ្ញវត្ថុ។ យើងបានគោរពយ៉ាងម៉ឺងម៉ាត់ ចំពោះច្បាប់ និងបទប្បញ្ញត្តិនានា ដែលដាក់ចេញដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងក្របខ័ណ្ឌត្រួតពិនិត្យកំណត់ដោយធនាគារជាតិនៃកម្ពុជា (NBC)។

ក្របខ័ណ្ឌនៃការប្រតិបត្តិតាមនេះ គឺជាគន្លងដឹកនាំសកម្មភាព របស់យើង ដើម្បីធានាបាននូវការអនុវត្តន៍ ហិរញ្ញវត្ថុ ប្រកបដោយការទទួលខុសត្រូវការគ្រប់គ្រងហានិភ័យយ៉ាងប្រុងប្រយ័ត្ន និងការការពារ ចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធគ្រប់កម្រិត។

ដើម្បីលើកកម្ពស់តម្លាភាព និងស្របតាមស្តង់ដារអន្តរជាតិ **សហការ** បាន អនុវត្តស្តង់ដារ កម្ពុជា-អន្តរជាតិ សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសតូច និងមធ្យម (CIFRS for SMEs) ចាប់ពីឆ្នាំ 2019។

ចាប់តាំងពីពេលនោះមក យើងបានធានាឱ្យមានការរាយការណ៍ហិរញ្ញវត្ថុ ត្រឹមត្រូវ ទាន់ពេលវេលា និងពេញលេញជានិច្ច។ របាយការណ៍ហិរញ្ញវត្ថុ របស់យើងត្រូវបានសវនកម្មជារៀងរាល់ឆ្នាំដោយសវនករឯករាជ្យ ដែលមានការទទួលស្គាល់ ហើយសម្រាប់ឆ្នាំ2024 ក្រុមហ៊ុន Fii & Associate Co., Ltd.គឺជាសវនករឯករាជ្យ របស់យើង។

ការប្តេជ្ញាក្នុងការប្រតិបត្តិទៅតាមបទប្បញ្ញត្តិ និងការរាយការណ៍ហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់នេះ ឆ្លុះបញ្ចាំងពីការតាំងចិត្តចំពោះចីរភាព នៃស្ថាប័នប្រសិទ្ធភាពនៃប្រតិបត្តិការ និងការជឿទុកចិត្តពីសាធារណជន របស់ **សហការ**។

ខណៈពេលយើងបន្តការរីកចម្រើន យើងនៅតែផ្តោតលើការពង្រឹង ប្រព័ន្ធអភិបាលកិច្ច និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីគាំទ្រការជោគជ័យរយៈពេលវែង និងការផ្តល់សេវាប្រកបដោយការទទួលខុសត្រូវ ចំពោះសហគមន៍របស់យើង។





# ៥

# របាយការណ៍ហិរញ្ញវត្ថុ
# ដែលបានធ្វើសវនកម្ម

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការដាក់ជូននូវរបាយការណ៍របស់ខ្លួន ដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

## សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដែលប្រកបដោយនិរន្តរភាពចំពោះសហគ្រាសធុនតូច និងមធ្យម និងគ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនោះទេ។

## លទ្ធផលនៃហិរញ្ញវត្ថុ

| | ២០២៤ | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់(ខាត)/ចំណេញមុនដកពន្ធ | (៧៦, ៦៦៦) | (៣១២,១០៨) |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១០០,៩៩៥) | (៤១១,១៥១) |
| ប្រាក់(ខាត)/ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ | (១៧៧,៦៦១) | (៧២៣,២៥៩) |

## ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ ឱ្យមានការបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទនោះទេ។

## ដើមទុន

ដើមទុនដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មានចំនួន ៣,៦០០,០០០ ដុល្លារអាមេរិក (២០២៣៖ ៣,៦០០,០០០ដុល្លារអាមេរិក) ដែលក្នុងនោះមួយភាគហ៊ុនមានតម្លៃស្មើនឹង ១ ដុល្លារអាមេរិក។ ភាគហ៊ុន និងរចនាសម្ព័ន្ធភាគហ៊ុនរបស់ក្រុមហ៊ុនលម្អិតត្រូវបានលាតត្រដាងនៅកំណត់សម្គាល់ ១៩។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាវិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឱ្យចំនួន នៃការលុបបំបាត់ចោលឥណទានអាក្រក់ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចលក់បាន នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

i. ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

ii. បំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទ ក្រៅអំពីប្រតិបត្តិការអាជីវកម្ម ធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់នោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរែកញែក នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថាលទ្ធផល នៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្ត ដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្តនិងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថានៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឱ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សម្គាល់ ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទរាយការណ៍មានរាយនាមដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក បុល វ៉ាន់នៀត | ប្រ.ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ |
| លោក. យ៉ាម៉ាស៊ីតា តាកាហ៊ីរ៉ូ | អភិបាល និងប្រធាននាយកហិរញ្ញវត្ថុ |
| លោក. មីយ៉ាអឹឈិ តូស៊ីហ៊ីរ៉ូ | អភិបាលឯករាជ្យ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាង ដែលគោលបំណងជួយដល់ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនដើម្បីទទួលបាននូវអត្ថប្រយោជន៍ ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃមួយទៀតឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរាប់បញ្ចូលក្នុងចំនួនសរុប នៃលាភការដែលបានទទួល ឬកំណត់នឹងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេង ដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេង ដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ក្នុងកម្រិតជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS for SMEs")។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលត្រូវ៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលនយោបាយទាំងនេះ ប្រកបដោយសង្គតិភាព។

(ii) អនុលោមទៅតាម CIFRS for SMEs ឬប្រសិនបើប្រាសចាកពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវគឺត្រូវតែបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់ចំនួន នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(iv) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនចំពោះការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(v) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាព ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្ត នូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សហការ** ភីអិលស៊ី សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រ ១០ ដល់ ៥២ ថាបានបង្ហាញនូវភាពត្រឹមត្រូវ ក្នុងកម្រិតជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

<< បានចុះហត្ថលេខា >>

លោក បុល វ៉ាន់នៀត
ប្រធាន និងប្រធាននាយកប្រតិបត្តិ
ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥

# របាយការណ៍របស់សវនករឯករាជ្យ
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សហការ** ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងរបាយការណ៍លទ្ធផលលម្អិតរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រ ១០ ដល់ ៥២។ ជាមតិរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវ ក្នុងកម្រិតជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (“CIFRS for SMEs”)។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោម ទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះត្រូវបានរៀបរាប់បន្ថែមទៀត នៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវ របស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាព ពីក្រុមហ៊ុនស្របតាមតម្រូវការនៃក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញតាមក្របខណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗ ស្របតាមតម្រូវការទាំងនោះ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋាន ក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ការទាញចំណាប់អារម្មណ៍លើបញ្ហា - ព័ត៌មានប្រៀបធៀប

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់ ២៧ នៃរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញថា ព័ត៌មានប្រៀបធៀប ដែលបានបង្ហាញនាថ្ងៃទ៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ត្រូវបានកំណត់ឡើងវិញ។ មតិសវនកម្មរបស់យើងខ្ញុំ មិនត្រូវបានកែប្រែដោយសារបញ្ហានេះទេ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្ម ដោយសវនករផ្សេងទៀតដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី26 ខែមេសា ឆ្នាំ2024 ថារបាយការណ៍នោះមានភាពត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍របស់សវនករមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនៅទំព័រ 1 ដល់ទី 5 ចំណែកឯរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនរំពឹងថានឹងផ្តល់ឱ្យយើងខ្ញុំក្រោយកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។ មតិរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានបញ្ចេញការសន្និដ្ឋានជាក់លាក់បន្ថែមលើនេះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ឬទេ។ ប្រសិនបើការមានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាម CIFRS for SMEs ហើយនឹងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈកិច្ចទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ចមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្ម របាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេល នៃការធ្វើសវនកម្មដោយអនុលោម ទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។ ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យ នៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាង ដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋាន ក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញ នូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណង ដើម្បីរៀបចំនូវនីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង របស់ក្រុមហ៊ុនឡើយ។

- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាន និរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើ ភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថា តើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្ត លើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍ របស់យើងខ្ញុំដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទ នៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឱ្យក្រុមហ៊ុនបញ្ឈប់នូវ និរន្តរភាពនៃអាជីវកម្ម។

- វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចចំពោះកត្តាពាក់ព័ន្ធនឹងសវនកម្មរួមមានជាអាទិ៍ វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាសវនកម្មជាសារវន្តរួមបញ្ចូលទាំងចំណុចខ្វះខាត នៃការគ្រប់គ្រងផ្ទៃក្នុង ដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន អេហ្វអាយអាយ & អឹសូស៊ីអេត

<< បានចុះហត្ថលេខា >>

ឈុន ម៉ារ៉ា<br>
នាយកសវនករ<br>
ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>
ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

**នាកាលបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៤**

| | | ២០២៤ | | ២០២៣ (កំណត់ឡើងវិញ) | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ១៣៧,៤០៧ | ៥៥៣,០៦៣ | ៣០,៦២៣ | ១២៥,០៩៥ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៥ | ១៨៤,០៦៥ | ៧៤០,៨៦២ | ១៨១,៧២៣ | ៧៤២,៣៣៨ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | ៦ | ១,០៧៩,០០៧ | ៤,៣៤៣,០០៣ | ៣៦០,០៤០ | ១,៤៧០,៧៦៣ |
| ឥណទានផ្តល់ដល់អតិថិជន | ៧ | ៨,៧៦៤,៩៨៤ | ៣៥,២៧៩,០៦១ | ៩,៤៧៩,៤៩៥ | ៣៨,៧២៣,៧៣៧ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ៥៤,៤២១ | ២១៩,០៤៥ | ៨០,៩៨៥ | ៣៣០,៨២៤ |
| ទ្រព្យ និងបរិក្ខារ | ៩ | ៨៤,៤៦៨ | ៣៣៩,៩៨៤ | ៩២,២២១ | ៣៧៦,៧២៣ |
| ទ្រព្យសកម្មអរូបី | ១០ | ២៤,៦៦១ | ៩៩,២៦១ | ២៤,៤១៧ | ១១១,៩៩៨ |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | ១៣.២ | - | - | ១១,៤៥០ | ៤៦,៧៧៣ |
| **ទ្រព្យសកម្មសរុប** | | **១០,៣២៩,០១៣** | **៤១,៥៧៤,២៧៩** | **១០,២៦៣,៩៥៤** | **៤១,៩២៨,២៥១** |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១១ | ១៣១,២៤២ | ៥២៨,២៥០ | ៧៧,៨២៥ | ៣១៧,៩១៦ |
| ប្រាក់កម្ចី | ១២ | ៨,៤៣០,៩៨៩ | ៣៣,៩៣៤,៧៣១ | ៨,៣៣១,២០៤ | ៣៤,០៣២,៩៦៨ |
| បំណុលពន្ធអប្បបរមា | ១៣.៣ | ១,៤៤៦ | ៥,៨២០ | ១,៤៧៣ | ៦,០១៧ |
| ពន្ធពន្យារជាបំណុលសុទ្ធ | | ៨៩,៥៤៥ | ៣៦០,៤១៩ | - | - |
| បំណុលសរុប | | **៨,៦៥៣,២២២** | **៣៤,៨២៩,២២០** | **៨,៤១០,៥០២** | **៣៤,៣៥៦,៩០១** |
| មូលធន | | | | | |
| ដើមទុន | ១៤ | ៣,៦០០,០០០ | ១៤,៥១២,១០០ | ៣,៦០០,០០០ | ១៤,៥១២,១០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៥ | ៥២៩,០៣៥ | ២,១៥៥,៣២៩ | ៦០,៤៨៧ | ២៤៧,៨៧០ |
| ប្រាក់ខាតបង្គរ | | (២,៤៥៣,២៤៤ | (៩,៩២៤,៧៩៤) | (១,៨០៧,០៣៥) | (៧,២៩៤,០៧៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ២,៤២៤ | - | ១០៥,៤៥៦ |
| **មូលធនសរុប** | | **១,៦៧៥,៧៩១** | **៦,៧៤៥,០៥៩** | **១,៨៥៣,៤៥២** | **៧,៥៧១,៣៥០** |
| **បំណុល និងមូលធនសរុប** | | **១០,៣២៩,០១៣** | **៤១,៥៧៤,២៧៩** | **១០,២៦៣,៩៥៤** | **៤,១៩២៨,២៥១** |

# របាយការណ៍ចំណូលលម្អិត

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤**

| | | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) |
| ចំណូលពីការប្រាក់ | **១៦** | ១,៤២៥,៣៧៦ | ៥,៨០២,៧០៦ | ១,៤៥៤,៨៧៤ | ៥,៩៧៩,៥៣២ |
| ចំណាយលើការប្រាក់ | ១៧ | (៤៣៨,៨៣៣) | (១,៧៨៦,៤៨៩) | (៤១១,៦៩០) | (១,៦៩២,០៤៦) |
| **ចំណូលការប្រាក់សុទ្ធ** | | ៩៨៦,៥៤៣ | ៤,០១៦,២១៧ | ១,០៤៣,១៨៤ | ៤,២៨៧,៤៨៦ |
| ចំណូលផ្សេងៗ | ១៨ | ១៥៦,៤៨០ | ៦៣៧,០៣០ | ១២២,១៨០ | ៥០២,១៦០ |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | ៧ | (៩៣,១៣០) | (៣៧៩,១៣២) | (៣៣,៥២០) | (១៣៧,៧៦៧) |
| ចំណាយបុគ្គលិក | ១៩ | (៧៧១,២៩៣) | (៣,១៣៩,៩៣៤) | (៧០៥,៥២១) | (២,៨៩៩,៦៩១) |
| រំលស់ | | (២៣,៣៨៩) | (៩៥,២១៧) | (៣៣,៤១១) | (១៣៧,៣១៩) |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | ២០ | (៣១៥,៦៩៨) | (១,២៨៥,២០៧) | (៣០១,៨៥៨) | (១,២៤០,៦៣៦) |
| ចំណាយពន្ធអប្បបរមា | **១៣.៤** | (១៦,១៧៩) | (៦៥,៨៦៥) | (១៥,៦០៤) | (៦៤,១៣២) |
| **ប្រាក់(ខាត)/ចំណេញមុនដកពន្ធ** | | (៧៦,៦៦៦) | (៣១២,១០៨) | ៧៥,៤៥០ | ៣១០,១០១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៣.៤ | (១០០,៩៩៥) | (៤១១,១៥១) | (៤,៣៧៣) | (១៧,៩៧៣) |
| **ប្រាក់(ខាត)/ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (១៧៧,៦៦១) | (៧២៣,២៥៩) | ៧១០៧៧ | ២៩២,១២៨ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១០៣,០៣២) | - | (៥៨,៨១៦) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | (១៧៧៦៦១) | (៨២៦,២៩១) | ៧១,០៧៧ | ២៣៣,៣១២ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤

| | ដើមទុន | | ដើមទុនបន្ថែម | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល |
| **នាថ្ងៃទី១ ខែ មករា ឆ្នាំ២០២៣** | ៣,៣០០,០០០ | ១៣,២៧៧,០០០ | ៣០០,០០០ | ១,២៣៥,១០០ | ៨,៨៨៤ | ៣៥,៧៨២ | (១,៨២៦,៥០៩) | (៧,៣៧៤,១១៦) | - | ១៦៤២៧២ | ១,៧៨២,៣៧៥ | ៧,៣៣៨,០៣៨ |
| ការផ្ទេរពីដើមទុនបន្ថែម | ៣០០,០០០ | ១,២៣៥,១០០ | (៣០០,០០០) | (១,២៣៥,១០០) | - | - | - | - | - | - | - | - |
| លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | ៧១,០៧៧ | ២៩២,១២៨ | - | - | ៧១,០៧៧ | ២៩២,១២៨ |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ៥១,៦០៣ | ២១២,០៨៨ | (៥១,៦០៣) | (២១២,០៨៨) | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (៥៨,៨១៦) | - | (៥៨,៨១៦) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | - | - | ៥១,៦០៣ | ២១២,០៨៨ | ១៩,៤៧៤ | ៨០,០៤០ | - | (៥៨,៨១៦) | ៧១,០៧៧ | ២៣៣,៣១២ |
| **នាថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣** | ៣,៦០០,០០០ | ១៤,៥១២,១០០ | - | - | ៦០,៤៨៧ | ២៤៧,៨៧០ | (១,៨០៧,០៣៥) | ៧,២៩៤,០៧៦) | - | ១០៥,៤៥៦ | ១,៨៥៣,៤៥២ | ៧,៥៧១,៣៥០ |
| | | | | | | | | | | | | |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤** | ៣,៦០០,០០០ | ១៤,៥១២,១០០ | - | - | ៦០,៤៨៧ | ២៤៧,៨៧០ | (១,៨០៧,០៣៥) | (៧,២៩៤,០៧៦) | - | ១០៥,៤៥៦ | ១,៨៥៣,៤៥២ | ៧,៥៧១,៣៥០ |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | (១៧៧,៦៦១) | (៧២៣,២៥៩) | - | - | (១៧៧,៦៦១) | (៧២៣,២៥៩) |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ៤៦៨,៥៤៨ | ១,៩០៧,៤៥៩ | (៤៦៨,៥៤៨) | (១,៩០៧,៤៥៩) | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗ** | | | - | - | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (១០៣,០៣២) | - | (១០៣,០៣២) |
| **សរុបលទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | - | - | ៤៦៨,៥៤៨ | ១,៩០៧,៤៥៩ | (៦៤៦,២០៩) | (២,៦៣០,៧១៨) | - | (១០៣,០៣២) | (១៧៧,៦៦១) | (៨២៦,២៩១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | ៣,៦០០,០០០ | ១៤,៥១២,១០០ | - | | ៥២៩,០៣៥ | ២,១៥៥,៣២៩ | (២,៤៥៣,២៤៤) | (៩,៩២៤,៧៩៤) | - | ២,៤២៤ | ១,៦៧៥,៧៩១ | ៦,៧៤៥,០៥៩ |

# របាយការណ៍លំហូរសាច់ប្រាក់

**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤**

| | ២០២៤ | | ២០២៣(កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារ អាមេរិក | ពាន់រៀល (សម្គាល់២.៤) | ដុល្លារ អាមេរិក | ពាន់រៀល (សម្គាល់២.៤) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់(ខាត) / ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | (១៧៧,៦៦១) | (៧២៣,២៥៩) | ៧១,០៧៧ | ២៩២,១២៨ |
| និយ័តភាពលើ៖ | | | | |
| ចំណាយលើការប្រាក់ | ៤៣៨,៨៣៣ | ១,៧៨៦,៤៨៩ | ៤១១,៦៩០ | ១,៦៩២,០៤៦ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១០០,៩៩៥ | ៤១១,១៥១ | ៤,៣៧៣ | ១៧,៩៧៣ |
| ការខាតបង់លើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន | ៩៣,១៣០ | ៣៧៩,១៣២ | ៣៣,៥២០ | ១៣៧,៧៦៧ |
| រំលស់ | ២៣,៣៨៩ | ៩៥,២១៧ | ៣៣,៤១១ | ១៣៧,៣១៩ |
| ចំណាយពន្ធអប្បបរមា | ១៦,១៧៩ | ៦៥,៨៦៥ | ១៥,៦០៤ | ៦៤,១៣២ |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | - | - | (១០,៣៥៤) | (៤២,៥៥៥) |
| | ៤៩៤,៨៦៥ | ២,០១៤,៥៩៥ | ៥៥៩,៣២១ | ២,២៩៨,៨១០ |
| បម្រែបម្រួលនៃ៖ | | | | |
| ឥណទានផ្តល់ដល់អតិថិជន | ៦២១៣៨១ | ២,៥២៩,៦៤២ | (១,២៥៦,៥៨៨) | (៥,១៦៤,៥៧៧) |
| ទ្រព្យសកម្មផ្សេងៗ | ២៦,៥៦៤ | ១០៨,១៩២ | (៣៦,៨៦២) | (១៥១,៥០៣) |
| បំណុលផ្សេងៗ | ៥៣,៤១៧ | ២១៧,៤៦១ | (៨២,៥៨១) | (៣៣៩,៤០៨) |
| **សាច់ប្រាក់សុទ្ធទទួលបានពី / (ប្រើប្រាស់ក្នុង) ប្រតិបត្តិការ** | **១,១៩៦,២២៧** | **៤,៨៦៩,៨៤០** | **(៨១៦,៧១០)** | **(៣,៣៥៦,៦៧៨)** |
| ពន្ធអប្បបរមាដែលបានបង់ | (១៦,២០៦) | (៦៥,៩៧៥) | (១៥,១០១) | (៦២,០៦៥) |
| **សាច់ប្រាក់សុទ្ធទទួលបានពី / (ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | **១,១៨០,០២១** | **៤,៨០៣,៨៦៥** | **(៨៣១,៨១១)** | **(៣,៤១៨,៧៤៣)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (១២,៨៨០) | (៥២,៤៣៤) | (១០១,៣៧០) | (៤១៦,៦៣១) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | - | - | ២៦,៧៦០ | ១០៩,៩៨៤ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **(១២,៨៨០)** | **(៥២,៤៣៤)** | **(៧៤,៦១០)** | **(៣០៦,៦៤៧)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ៤០០,០០០ | ១,៦២៨,៤០០ | ១,២៥០,០០០ | ៥,១៣៧,៥០០ |
| ការប្រាក់ដែលបានបង់ | (៤៣៩,០៤៨) | (១,៧៨៧,៣៦៤) | (៤១១,៦៩០) | (១,៦៩២,០៤៦) |
| ការទូទាត់សងប្រាក់កម្ចី | (៣០០,០០០) | (១,២២១,៣០០) | (៥៥០,០០០) | (២,២៦០,៥០០) |
| ប្រាក់តម្កល់ធានាលើដើមទុន | - | - | (១៥,០០០) | (៦១,៦៥០) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង) / ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | **(៣៣៩,០៤៨)** | **(១,៣៨០,២៦៤)** | **២៧៣,៣១០** | **១,១២៣,៣០៤** |
| **ការកើនឡើង/(ថយចុះ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | **៨២៨,០៩៣** | **៣,៣៧១,១៦៧** | **(៦៣៣,១១១)** | **(២,៦០២,០៨៦)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី១ ខែមករា | ៣៩២,៣៨៦ | ១,៦០២,៨៩៦ | ១,០២៥,៤៩៧ | ៤,២២១,៩៧១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៦១,៦៣៥) | - | (១៦,៩៨៩) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី៣១ ខែធ្នូ (កំណត់សម្គាល់ ២១)** | **១,២២០,៤៧៩** | **៤,៩១២,៤២៨** | **៣៩២,៣៨៦** | **១,៦០២,៨៩៦** |

សហការ

ទាំងអស់គ្នាដើម្បីភាពរីកចម្រើន!

www.sahakamfi.com.kh Sahaka MFI Sahaka_MFI Sahaka_MFI Sahaka MFI

023 967 779, 061 500 979, 093 500 979 #6CD, Poland Republic Blvd (163), Sangkat Veal Vong, Khan 7 Makara, Phnom Penh